- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារភាសាខ្មែរ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅសំរាប់គ្រូ « ភាសាខ្មែរថ្នាក់ទី ១ » ដែលជាស្នាដៃ និពន្ធរបស់គណៈកម្មការភាសាខ្មែរ បឋមសិក្សា នៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំ យុវជន និង កីឡា និងរៀបរៀង ដោយ លោក **លី សុមុនី** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំណេះទូទៅ ។

**ប្រការ ២** : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយ បណ្ណាល័យ នាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យ សិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៦

**ប្រកាសលេខ : ៤១៦ អយក.ប្រក**

**ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យ ក្រាំងយ៉ូវ ទៅជា « អនុវិទ្យាល័យ ហ៊ុន សែន ក្រាំងយ៉ូវ » ស្ថិតនៅក្នុង ស្រុកស្អាង ខេត្ត កណ្តាល**

**រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១

វិច្ឆិកា ១៩៩៣ ស្ដីពីការតែងតាំង រាជ រដ្ឋាភិបាលកម្ពុជា ។

- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែល ប្រកាស អោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។
- បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្ដីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- យោងលិខិតរបស់គណៈកម្មការសាងសង់អនុវិទ្យាល័យ ក្រាំងយ៉ូវលេខ ៣០/ ៩៦ អនុវិ.ក្រយ៉ ចុះថ្ងៃទី ២៨ កុម្ភៈ ១៩៩៦ ដោយមានចំនារបញ្ជូនពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្តកណ្ដាល ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ។

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយប្ដូរឈ្មោះ អនុវិទ្យាល័យ ក្រាំងយ៉ូវ ទៅជា « អនុវិទ្យាល័យ **ហ៊ុន សែន** ក្រាំងយ៉ូវ » ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

**ប្រការ ២** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋាន ចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា – ប្រធានមន្ទីរ អប់រំយុវជន និងកីឡាខេត្តកណ្ដាល និងនាយកអនុវិទ្យាល័យ ហ៊ុន សែន ក្រាំងយ៉ូវ មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**តុល ឡោះ**

* * *